# មន្តគាថាការពារខ្លួន

និងរបៀបរៀបចំថ្វាយគ្រូ រៀបរណ្តាប់ថ្វាយគ្រូ

ត្រូវរៀបចំស្លាធមិ១គូរ ម្ទូ៥ បារី៥ លាជ៥ ទឹកអប់ក្រអូប១ដប បាយសីបាក់ឆាម១គូរ ទៀនធំ ១គូរ សំពត់ស៥ហត្ថ ប្រាក់បុរាណ១រៀល ( បើគ្មានប្រាក់បុរាណទេ ត្រូវដាក់ក្រដាសប្រាក់១0រៀល ថ្មី៤ សន្លឹក( ៤Ō ) ជំនួសក៏បាន និងផេះ១ត្រឡោក ។

*គាថាសម្រាប់អញ្ជើញគ្រូ*

ឧម្មះ អញ្ជើញគ្រូ ព្រះរាហ៊ូអាគ្នេយ៏ ចាត់អារក្សធំទាំង១ម៉ឺនលោកធាតុមកជួយទល់ខ្នង នៃពួក ពលអញខ្ញុំ ស្វាហះ ( សូត្រ៣ចប់ )

ចំណាំ គាថានេះអាចប្រើរំលាយសត្រូវ សូត្រ១២ចប់ គឺសរសេរឈ្មោះសត្រូវមូរនឹងទៀនអុជ សូត្រឱ្យរលាយតាមទៀន នឹងបានសម្រេចដូចសេចក្តីប្រាថ្នាហោង ។

..........................

## កថាខណ្ឌទី១

អញ្ជើញទសបារមីព្រះពុទ្ធ

**នមោតស្សះ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** ( សូត្រ៣ចប់ )

ពុទ្ធំ អរតនំ ករោមិក ( ទុតិយម្បិះ , តតិយម្បិះ )

ធម្មំ អរតនំ ករោមិក ( ទុតិយម្បិះ , តតិយម្បិះ )

សង្ឃំ អរតនំ ករោមិក ( ទុតិយម្បិះ , តតិយម្បិះ )

+ ឧកាស វន្ទា មុនី ឥសី ភគវា សព្វំ អរតនំ វន្ទាមិ ។ ( ទុតិយម្បិះ , តតិយម្បិះ )

+ឧកាស វន្ទា មាតា បិតុ គុណំ ភគវា សព្វំ អរតនំ វន្ទាមិ ។ ( ទុតិយម្បិះ , តតិយម្បិះ )

+ឧកាសះ ឧកាសះ សូមអារាជនា ព្រះទាំង៥ព្រះអង្គ ព្រះកកុសន្ធោ ព្រះកោនាកមនោ ព្រះកស្សបោ ព្រះសក្យមុនីគោតម ព្រះសិអារ្យមេត្រី អារាធនា លេខយ័ន្តមន្តគាថា ទាំងប្រាំបីម៉ឺន បួនម៉ឺន ព្រះធម្មក្ខន្ធមួយពាន់ម្តៃ សូមអំណាចតេជះ សូមឈ្នះចិត្តទ្រឹះឫស្សា អន្សត្ថិរិយា កន្លងលែងទុក្ខភ័យ អាសន្នអន្តរាយ សូមសុខប្រសើរ ដំណើរដូចព្រះអង្គហោង ។ ( សូត្រ៧ចប់ )

## កថាខណ្ឌទី២

គាថាសំរាប់ដាស់កន្សែងយ័ន្ត កថាយ័ន្ត អាវយ័ន្តតេជះ

ឧម្មះ ដាស់កឹង មហាដាស់កឹង ទើបគ្រូប្រើអញដាស់ទាំងរនាំង អាគមគាថា ដាស់ ទាំងកន្លែងលេខយ័ន្ត មន្តគាថា ឧម្មះ ដាស់មហាសារពើដាស់ ។ (សូត្រ៧ចប់)

## មន្តគាថាដាស់កថា ឬ កន្សែងយ័ន្ត

នាគោ អគច្ឆេយ្យ អាគច្ឆាហីតិ បាលីអើយ វត្តញេ អាគច្ឆេយ្យ អាគច្ឆាហិ មាមិមមះ ។ (សូត្រ៧ចប់)

.....................................

## មន្តគាថាប្រសិទ្ធីអាវតេជះ

ឯហិ គាថា ឯហិគាថំ ឯហិនាមំ ឯហិមមះ ។ (សូត្រ៧ចប់) ព្រះគ្រូ ថាច់ ឈូក

..................................

## មន្តគាថានេះប្រើនៅពេលលើកអាវតេជះពាក់

ឆ្អឹងអញអើយបីដូចដែក ស្បែកអញអើញ បីដូចមហាឥសីសុទ្ធ កាប់សាច់ក្រឡាច់ឆ្អឹង ប្រែប្រឹង រឹងសាច់ ឱម្មសិទ្ធិស្វាហះ ។ (សូត្រ៣ចប់)

......................................

## គាថានេះប្រើនៅពេលលើកខ្សែកថាពាក់

ពុទ្ធំគង់ ធម្មំគង់ សង្ឃំគង់ (សូត្រ៣ចប់)

ចេញប្រតិបត្តិការនឹងបានឈ្នះទមិឡប្រាកដណាស់ ។ ព្រះគ្រូ ថាច់ ឈូក

..............................................



## ឈ្មោល

យន្ត័នេះដាក់ជាប់ខ្លួន ទមិឡ្យឃើញស្លុតរត់បាតអស់



## ញី

យន្ត័នេះចា  កថា រឺ ចា កន្សែង ប្រើសាកសិទ្ធិណាសហោង។

ពាក់ រឺ ក្រវាត់ចង្កេះត្រូវសូត្រដាស់គាថារំលឹកគុណ

គ្រូជាមុនសិន



យន្ត័ខ្មៅ១៦ចាដាក់ជាប្រាក់ស្ពាន់ រឺ ចាជាកន្សែងយន្ត័ក៏បាន

ពូកែសាកសិទ្ធិណាស ។ ក្មេងស្កន់ រឺ រវើរវាយយំយប់

រំដាក់ជាប់កជាហោង ។

---





## កថាខណ្ឌទី៣

គាថាដាស់អង្គប្រាណ កាប់មិនមុត បាញ់មិនត្រូវ គង់ឆ្អឹង គង់សាច់ បញ្ចៀសសារពើគ្រាប់គ្រប់ យ៉ាង ៖

មេទី១

ពុទ្ធំ ឧទ្ធំ អធោ

ធម្មំ ឧទ្ធំ អធោ

សង្ឃំ ឧទ្ធំ អធោ

មេទី ២

សិលាថ្លៃថ្លា សច្ចាបរមាលា បួនកោដ សោតតានំ សច្ចំបាំងបាត់ បាំងជិតទៅ សូមខ្ញុំរស់ នៅព្រះឥសី ឱ្យពរទាំងទិសឧត្តរ ទាំង៨ហោងជុំ អស់ទាំងហនុមាន បាំងខ្លួនខ្ញុំបាន ឱមសិទ្ធិស្វាហះ ។

(សូត្រ៧ចប់ និងប្រើ១០០គុណក៏បាន)

ចម្លងតាមក្បួន លោកវរសេនីយ៍ទោស នាង ឈុំ (ពោធិសាត់)

..............................

នេះគាថាភាវនាជាប់នៅនឹងមាត់ ការពារគ្រាប់បែកកប់ ចម្រូង និង ការពួនស្ទាក់ របស់ខ្មាំង សម្មាសម្ពុទ្ធោ អរហំ ។

បើមានសត្រូវ មានគ្រាប់បែកកប់ ឬចម្រូងនៅខាងមុខ ខ្លួនយើងនឹងញាប់ញ័រ ត្រូវប្រុងប្រយ័ត្ន បើមានគ្រាប់ផ្ទុះនៅមុខយើងហើយ ត្រូវផ្លាស់តួភាវនា នមះ សះតះ កាំភ្លើងខ្មាំងនឹងបាញ់មិនចេញ ផ្ទុះបែកកាណុង ។ (ចម្លងតាមក្បួន លោកវរសេនីយ៍ទោ នាង ឈុំ (ពោធិសាត់)

................................

## កថាខណ្ឌទី៤

គាថាបំបាំងភ្នែកខ្មាំងសត្រូវមិនឱ្យមើលយើងឃើញ

ប៉ោក្វាំក្វាំ រកណា កជាណំ (ភាវនាជាប់)

គាថានេះកាលព្រះសម្មាសម្ពុទ្ធទ្រង់ភាវនា ផ្ទាញ់ផ្ទាល ពួកនិគ្រន្ថអន្យតិរ្ថិយមិនឱ្យមើលព្រះអង្គ ឃើញ ។

.................................

## កថាខណ្ឌទី៥

កាច់មែកឈើដោតបិទបាំងខ្លួន សូត្របំបាំងខ្លួន សត្រូវពុំអាចមើលឃើញឡើយ ។

+អាយន្ត ភន្តោ ទានសីលា ខេក្ខម្មបញ្ញា វិរិយ ទិក្ខន្តិ សច្ចា ទិដ្ឋា មេត្តា ឧបេក្ខា យុទ្ធាយរោ តណ្ហា ថអារុទ្ធា និយេបារមី តានុភាវេន សព្វេ មានេបលាយឹងសុ ។ (សូត្រ៣ចប់)

+នមោ មេបាំង កកើតរូបំ ព្រះព្រហ្មប្រកឱ្យឥសីបាំងមុខ ព្រះឥន្ទបាំងក្រោយ ព្រះព្រហ្ម ប្រោសអោយឈ្នះអស់សត្រូវ ។ (សូត្រ៧ចប់)

ចម្លងតាមក្បួនព្រះសពព្រះនាម ជូន មេគណវត្តសំពៅ ខេត្តបាត់ដំបង

## កថាខណ្ឌទី៦

គថាប្រក់ពល លើកកម្លាំងចិត្តឱ្យក្លាហាន

ឥន្ទសារិ ទេសារិ ចក្កវត្តិសារិ ព្រហ្មសារិ មហាព្រហ្មសារិ ឥសីសារិ មហាឥសីសារិ ឥសូរព្រហ្មំ មហាឥសូរព្រហ្មំ មុនីសារិ មហាមុនីសារិ សប្បុរិសសារិ មហាសប្បុរិសសារិ ពុទ្ធព្រហ្មសារិ បច្ចេកពុទ្ធព្រហ្មសារិ ឥន្ទសីលំ ឥន្ទទានំ ឥន្ទនិខំ ឥន្ទបញ្ញំ ឥន្ទភាគំ ឥន្ទតព្វំ ឥន្ទយសំ ឥន្ទសុខំ ឥន្ទសេរំ ឥន្ទរូបំ ឥន្ទសេដ្ឋំ ឥន្ទមន្តំ ។ (យកទឹកមកប្រក់ព្រំ រួចសូត្រ៩ចប់)

គាថានេះពិសេសណាស់ ប្រក់ព្រំពល ឬដាស់ឫទ្ធិរបស់យើង បើមានពលណាចាញ់ក្រាបខ្នាំង ត្រូវហៅមកប្រក់ព្រំ និងមានជ័យជំនះមិនខាន ។

.....................................

## កថាខណ្ឌទី៧

សំរាប់ភាវនាពេលចូលប្រយុទ្ធ

ដៃក្ដាប់កាំភ្លើង ឬ កាំបិត ដាវឱ្យណែន តាំងស្មារតីឱ្យរឹងប៉ឹង តាំងចិត្តឱ្យក្លាហានមោះមុត ភ្នែកសម្លឹងឱ្យមុតចំទៅទិសដែលមានទមិឡសត្រូវ រួចភាវនាថា :

មេទី ១

មហាភនិខមលា បរិវតោ វិតោ (សូត្រ៧ចប់)

មេទី ២

នំ សុំ យុំ អុំ សុំ យុំ នំ (សូត្រ៧ចប់)

គាថានេះ កាលព្រះឥសីបញ្ចៀសព្រួញ ធ្នូ ស្នា និង ពួកពលមារ នៅក្នុងឥសិអបចនេ ឱ្យរន្ធត់ខ្លបខ្លាច ។(ចម្លងតាមក្បួន លោកអនុសេនីយ៍ឯក នាង ម៉ន (ពោធិសាត់))

..............................

## កថាខណ្ឌទី ៨

គាថានេះប្រើសំរាប់ពេលចេញដើរប្រតិបត្តិការត្រៀមចាំខ្មាំង ឬ ពេលប្រយុទ្ធ

សតិក ភន ភខ ឥអស គោស (ភាវនា)

គាថានេះកាលព្រះជនកសូត្រលើកម្លាំង បញ្ចៀសសត្រូវ ពួកពលមារ ធ្វើឱ្យព្រះអង្គឥតតក់ស្លុត អ្វីឡើយ ។ ត្រូវភាវនាគាថានេះឱ្យជាប់នឹងមាត់ ហើយត្រូវតាំងចិត្តអំណត់ខន្តីរំលោភប្រពន្ធគេ កុំប្លន់ទ្រព្យសម្បត្តិគេ កុំជេរប្រមាថម្តាយឪពុកគេជាដាច់ខាត ។

(ចម្លងតាមក្បួន)លោកអនុសេនីយ៍ទោ ប៊ុន លីគីវ ហៅ គាវ (កំពង់ស្ពឺ)

....................................

## កថាខណ្ឌទី ៩

គាថានេះត្រូវប្រើនៅពេលបោះជំរុំក្នុងព្រៃ ព័ទ្ធសីមាការពារសត្វសាហាវ ខ្មាំងសត្រូវគ្រប់យ៉ាងមិនឱ្យចូលមកជិតបាន បិត បារមីតា អហំ តះភះ កះសះតះ ។

គាថានេះត្រូវសូត្រដោយអត់ដង្ហើមឱ្យបាន៧ចប់ ហើយយកដី៨ដុំ ចោលទៅគ្រប់ទិសទាំង៨ គ្រវែងថយក្រោយ បែរមុខមករកពួកពលយើង ចម្ងាយពីកន្លែងពួកពលយើងនៅ ៧០ ឬ ៨០ម៉ែត្រ ។ មុននឹងគ្រវែងដី ១ដុំៗ ត្រូវសូត្រ ៧ចប់ អត់ដង្ហើម ។

(ចម្លងតាមក្បួន)

ព្រះគ្រូ ថាច់ ឈូក ហៅ ញឹម

ពេលកងពលយើងសំរាកក្នុងជំរុំ យប់ ឬ ថ្ងៃ ខ្មាំងផ្លោងគ្រាប់មកមិនត្រូវ ។ គប្បីសូត្រគាថាដូចតទៅ : សិរស្មិ មេពុទ្ធសេដ្ឋោ សារីបុត្តោ ច ទក្ខិណេ វាមបស្សេ មោគ្គលានោ បុរតោ បិដកត្តយំ បច្ឆិមេ មម អានន្ទោ ចតុទិសា ខីណាសវា សមន្តា លោកបាលា ចតន្ទព្រហ្មាច ទេវតា ឯតេសំ អានុភាវេន ហន្តា តេសំ ឧបទ្ទវេ ។

ចម្លងតាមក្បួន ព្រះគ្រូ ច័ន្ទ សាលី វត្តបុទុមវតីរាជវរារាម

**មន្តគាថាសូត្រសន្ទប់ពួកខ្មាំង សត្រូវឱ្យបាក់ខួបខ្លាចចុះចាញ់**

អចោ ព្យសី  ករាវ៉ាតេ  ហិរញ្ញហ វិជា វិជា  វរទដ្ឋ  ភយេ ភ្យាសោ  រក្ខមំមា  រជី  ជិន ។

( សូត្រ៣ចប់ ឬ ៩ចប់ ពេលព្ញសូរ ឬ ឃើញខ្មាំង)

ចម្លងតាមក្បួន លោកគ្រូ ជិន នាក់ ព្រះអនុគណវត្តអង្គសុរភី ( កំពង់ត្រាច កំពត)

**មន្តគាថាបំភ័ន្តស្មារតីសត្រូវឱ្យភាំងស្លុត**

ន បាំងឃោ មោ បាំងឃា ធា អាំងឡាំង សត្ថា ធនុំ អាកឡិតុំ ទត្វា វិស្សជ្ជេតំ នាទាសិ ។

( សូត្រ៣ចប់ ឬ ៧ចប់)

ចម្លងតាមក្បួន លោក កង សាផាន អ្នកតំណាងរាស្ត្រមណ្ឌលស្រែជា ( កំពត)

មន្តគាថាដាច់ស្មារតីឱ្យក្លាហាន មុនពេលចូលប្រយុទ្ធ ឬ ធ្វើការផ្សេងៗ

ឧ  ស  ស្រ  អ  ស  ស្រ ករវិតោ  ព្រហ្មសរោ  ឧសិកៈ ។

( សូត្រ៣ចប់ ឬ ៧ចប់ យកបាតដៃអង្អែលដើមទ្រូង)

ចម្លងតាមក្បួន លោកអាចារ្យ ឈូក សំ ( កំពត)

-----------------,,---------------

## ក្បួនវេទមន្ត

សិល្ប៍គាថា ផ្លុំ  ស្តោះ  នូវជំងឺផ្សេងៗ

ក្បួននេះលោកគ្រូចាស់ៗបានប្រើពិសោធន៏យ៉ាងស័ក្តិសិទ្ធិតជាច្រើនរយឆ្នាំកន្លងមកហើយ

ក្នុងប្រទេសកម្ពុជា ។ ជាពិសេសលោកបានរក្សាទុកចែកយើងគ្រប់គ្នារៀនសូត្រតរៀងទៅ ។

**មន្តគាថា ស្តោះ  ស្ពឹក  គ្រេច  ហើម**

មេទី ១

ឱមៈ លីដឹងទៅកាប់ដំបូក លូកដីឥដ្ឋ យកមកបិទដំបៅពាលា ពីងដឹងពីណា ពីកូនស្តេចកូនទេព្តា

ពីតាមហាឥសី ដាច់ស្បែកតស្បែក ដាច់សាច់តសាច់ ដាច់ឆ្អឹងតឆ្អឹង ដាច់សរសៃតសរសៃ ឱមសិទ្ធិស្វាហៈ

ត្រូវស្តាប់បង្គាប់អញ ជាគ្រូបាធ្យាយ  ។ ( សូត្រ៣ចប់ ផ្លុំស្តោះម្តង)

មេទី ២

ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ  លោកវិទូ អនុត្តរោ បុរិសទម្ម សារថិសត្ថា ទេវមនុស្សា នំពុទ្ធោ ភគវាតិ ។

ពុទ្ធំកំចាត់  ធម្មំកំចាត់  សង្ឃំកំចាត់

ពុទ្ធំកំចាយ  ធម្មំកំចាយ  សង្ឃំកំចាយ

ពុទ្ធំរលាយ  ធម្មំរលាយ  សង្ឃំរលាយ  ឱមសិទ្ធិស្វាហៈ ។ (សូត្រ៣ចប់ ផ្លុំស្តោះម្តង)

មេទី ៣

ឥមា មហាសុបិន ព្រះសុធនហៃរគម្ពីរ ឆ្នាំមមីព្រះអង្គចេញត្រាស ខែរះភ្លឺដូចមាស អស់ទាំងរាស្ត្រខំធ្វើបុណ្យ អ្នកណាមិនជឿបញ្ជូនទៅមុន  មះ  អះ  ឧះ ។

អរហំយើងខ្ញុំ ឱនបង្គំព្រះនាំនឹក ឱ្យទាន់ព្រះធម្មិក ព្រះអង្គចេញរៀប ព្រះសាសនា ធមិទាំង៨ម៉ឺន ៤ពាន់ច្រើនណាស់ណា មានទុក្ខអង្គគថា ព្រះសម្មាព្រះម្ចាស់ថ្ងៃ ព្រះអង្គអាសូរសត្វ ពិបាកកាត់ណាស់សព្វថ្ងៃ ទ្រង់យាងចេញចាកលៃ ខំប្រោសសត្វគ្រប់៧គ្នា ។

(សូត្រ៣ចប់ ផ្លុំស្តោះស្លា ព្រួសទឹកផង (៣ព្រឹកជាងហោង))

ទ្រនឹបគ្រូចេក១ស្និទ្ធ ប្រាក់៣០រៀល  (លោកនាយ នាង សាន់ (កំពត)

## គាថាស្តោះស្តន់ស័ក្តិសិទ្ធ

ឧមះ ស្តន់ទប់ ស្តន់ទល់ ស្តន់ហល់ ស្តន់ហើម ស្តន់ម្តាយដើម ស្តន់ស្វា ស្តន់ខ្លា ទើបគ្រូប្រើអញឱ្យស្តោះពេលព្រឹក ត្រជាក់ដូចត្រឡាច ស្តោះពេលល្ងាចត្រជាក់ដូចរនោងសាញ ឱមសិទ្ធិស្វាហៈ ។

(សូត្រ៧ចប់ ផ្លុំម្តង)

មេទី២

នះផាត់ មោះផាយ ពុះផាត់ឱ្យឆ្ងាយ ទ្វារិនាស្សន្តិ យះអសេសតោ ។ (សូត្រ៧ចប់ ផ្លុំម្តង នឹងជា ហោង)

(ចម្លងតាមក្បួន លោកគ្រូ ជុំ សេង នៅក្រុងភ្នំពេញ)

## គាថាស្តោះក្មេងភ្ញាក់ភ័យ យំយប់

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្សៈ (៣ចប់)

ឥតិបិសោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោលោកវិទូ អនុត្តរោ បុរិសទម្មសារថិសត្ថា ទេវមនុស្សានំ ពុទ្ធោ ភគភាតិ ។

ស្វាខាតោ ភគវតា ធម្មោ ធម្មំ នមស្សាមិ សុបដិបន្នោភគវតោ សាវកសង្ឃោ សង្ឃំ នមស្សាមិ ។

នៈ ផាត់ មោះ ផាយ ៗ ផាត់ឱ្យឆ្ងាយ ទ្វាះ វិនាសន្តិ យៈអសេសតោ ។

(សូត្រ៣ចប់ ប្រោះទឹក៣ព្រឹក ជាហោង)

(ចម្លងតាមក្បួន លោកគ្រូព្រះសព ងិន មេគណវត្តកំពង់ធំ)

## មន្តគាថាផ្លុំស្តោះត្រីអណ្តែងមុត និងសត្វអសិរពិសខាំ ទិច ឬប៉ះមុតហើមផ្សេងៗ

មេទី ១

ឱមៈ ពីងអើយពីងខ្ចី ពិសពីង៨ ស្រកីពីង៩ ពីងនៅទ្បេបទ្រិប ពីងកប់ភក់ជ្រៅ ទើបគ្រូប្រើអញ ឱ្យស្តោះពេលព្រឹកត្រជាក់ដូចត្រឡាច ស្តោះពេលល្ងាចត្រជាក់ដូចរនោងសាញ ឱមសិទ្ធិស្វាហៈ ។

(សូត្រ៧ចប់ ៣ព្រឹកជាហោង)

មេទី ២

ឱមៈ ពោះពីង ស្នែងពីងក្រទៃក ភ្នែកទីងក្រឡង់ ពុកមាត់ទីងត្រង់ ទីងពងលើស្មៅ ឱមៈព្រះនេត្រអញអើយចាំងថែងស្វាហាយ ។(សូត្រ៧ចប់ ៣ព្រឹកជាហោង) ចម្លងតាមក្បួន លោកតា ហ៊ីង

មេទី ៣

ទើបគ្រូប្រើអញឱ្យចិញ្ចឹម សត្វទន្ទើប១ជំពុះដែក ភ្នែកប្រាក់ ពាំពិសមេ(ឈ្មោះពស់វែក ឬមេរង) ទៅដាក់កណ្តាលសមុទ្រលង្កាមហាត្រៃវិស័យ ពាំពិសពីងទៅវិនាសន្តិ វិជ្ជតិ ។

ពិស បច្ចក្ខាមិ ធម្មំ សង្ឃំ បច្ចក្ខាមិ ។

ឧម្មៈទៅៗ ឮមាត់អញហៅ ខាវខ្សៀកលើសារ សាពណិមើល ។

(សូត្រ៧ចប់ ហើយស្តោះជាហោង) ចម្លងតាមក្បួនលោកតា វត្តស្ទឹងមានជ័យ

.................................

គាថានេះសំរាប់សូត្រចងមាត់សត្វសាហាវ និងសត្វអសិរពិសគ្រប់យ៉ាង

ត្រូវសូត្រអត់ដង្ហើម៧ចប់ ថា :

ធាឥម ស្វាសុ យឧមថ មខភំក្វាំ

បើកន្លែងណាមានព្រៃស្មសាន ឬព្រៃធំស្រោងស្រើងគួរឱ្យភ័យខ្លាច មុនពេលចូលទៅ ត្រូវសូត្រគាថាខាងក្រោមនេះថា :

ម អ ករណី ជើងខ្ញុំឈ្មោះ (...) ជាន់ដីសិទ្ធីស្វាហាយ ។

ពេលកំពុងសូត្រ ត្រូវយកម្រាមជើងស្តាំចុចដីហើយ សឹមដើរទៅ ខ្មោច ព្រាយបិសាច មនុស្សម្នាកាចសាហាវ សឹងខ្លាចអំណាច ហើយតាមថែរក្សាយើងហោង ។

...............................

## មន្តគាថាស្តោះ ផ្លុំពិសខ្ទុរ កម ពងបែកទឹក ឬ បូសខ្ទុរ

+ ឱម: ជលោ មហាជលំ ទឹកមាត់អញអើយ ទៅខាំមេក្រុបខ្ទុរ

ចេក: ជស: ។ (សូត្រ៣ចប់ ផ្លុំម្តង)

+សព្វេ ពុទ្ធា បឡាប្បត្តា បច្ចេកាណញ្ច យន្តានំ អរហន្តាណញ្ច ជតេជេន រខន្តុពុទ្ធា សព្វសោ ។

(សូត្រ៣ចប់ ស្រោចទឹកម្តង)

+មោឃស អារក្ខខ្ទុរ ព្រាយបវរ ជំទាវស្រីខ្មៅ អញស្រោចទឹកទៅ វិនាស្សន្តិ អសេសតោ ។

(សូត្រ៣ចប់ ផ្លុំបន្ទើរ៧ ជាហោង)

## បណ្តាំគ្រូ

មុននឹងប្រើគាថាស្តោះ ផ្លុំនីមួយៗ ត្រូវដុតធូប៥សរសៃ រំលឹកគុណគ្រូជានិច្ច ត្រូវ មានម្លូ ស្លា និងទឹក១ផ្តិលផង ។

......................................

## មន្តគាថាស្តោះ កើតពពែភ្នែក

នបុណ្យកំផែងកែវ ព្រះថោថេលែវ ឥតិ បិសោ ភគវា សម្មាសតិ (ប្រើ១០០គុណ សូត្រ៧ចប់)

ឧទ្ទំ អន្នោ ទ្នោ ឧទ្ទំ អទ្ធ ។

ប្រើ១០០គុណបានដូចក្តីប្រាថ្នា (សូត្រ៧ចប់ជាហោង)

<u>ចំណាំ</u> : ត្រូវយកអំបោះទៅចងម្រាមដៃ បើកើតភ្នែកឆ្វេង ចងម្រាមស្តាំ កើតភ្នែកស្តាំ ចងម្រាមឆ្វេង ជាប់រហូតដល់ពេលជា ។ (ចម្លងតាមក្បួនបូរាណ)

..............................

## គាថាស្តោះពិសរលាកភ្លើង ឬ ស្តោះផ្លុំក្រឡទែន

ទោធស សច្ច និម្មិតស្រះឯចុង យកធះ ថនិតជាទះ សិថិល ដោយចះ ស័ព្ទយក ធះជាហះ យក ទះជាតះ យក តះជាកះ យក កជាលះ យក យះជាជះ យក វះជាពះ យក បះជាផះ

(សូត្រ៧ចប់ ផ្លុំម្តង ៣ព្រឹក ជាហោង) លោកគ្រូ តែម វត្តទឹកល្អក់

ឱមះ ពិសតូច ពិសធំ ទើបគ្រូប្រើអញបណ្តេញពិសចេញ

ឱមសារពើពិស គ្រូប្រើអញស្តោះពិស ជាគ្រូបាធ្យាយ ហោង (សូត្រ៧ចប់) លោកគ្រូ សួង វង្ស

## បណ្តាំគ្រូ

គូររូបខ្លា ឬ នាគ ត្រង់កន្លែងហើម ។

## ព័ទ្ធបូសបណ្តើរកូន

នករំ មោករំ ពិសកំ បាបអហិមម (សូត្រនមោ៣ដង រួចសូត្រ៣ចប់)

## ព័ទ្ធបូសធំ

បុព្វមធោ ចិតមសរ សរេន វិយោជយេ អហិមម ។(សូត្រនមោ៣ដង រួចសូត្រ៣ចប់)

## បណ្តាំគ្រូ

បើបូសទាំងពីរមុខនេះវាទើបតែផ្តើមកើត ត្រូវសូត្រយកក្រមួនបង្ក្រាបទៅវិញ ។ តែបើឡើងធំហើយ គេត្រូវព័ទ្ធវាយោងមុខឡើង ឱ្យក្លាយបែកមុខតែម្តង ។

ចម្លងតាមក្បួន លោកតា យ៉ង់ អ៊ុន វត្តសំពោង

## មន្តគាថាកំផែងកែវ៧ជាន់

ពុទ្ធំ  សត្តរតន បាបារំ មេជីវិតំ យាវនិព្វានំ សរណំ គច្ឆាមិ ។

ធម្មំ  សត្តរតន បាបារំ មេជីវិតំ យាវនិព្វានំ សរណំ គច្ឆាមិ ។

សង្ឃំ  សត្តរតន បាបារំ មេជីវិតំ យាវនិព្វានំ សរណំ គច្ឆាមិ ។(សូត្រ៣ចប់ ឬ ៧ចប់)

## របៀបប្រើពីរយ៉ាង គឺ

១-ការពារសត្វសាហាវ ខ្មោច ព្រាយ ។

២-ព័ទ្ធសីមាស្រីទើបឆ្លងទន្លេ ដែលបិសាចចេះតែមកបៀតបៀន បន្ទាចឱ្យភ័យ ឱ្យភ្ញាក់ ស្រែក រវើរវាយ ។

AZCambodia.com ABCCambodia.com AngkorDaily.com AngkorPost.com AngkorLink.com

ចម្លងតាមក្បួន លោកតា ឆែ បូ វាលស្រីស្រណោះ

## មន្តគាថាស្តោះសត្វគោចាប់ មានគោ ក្របី សេះ ជាដើម

ឧមសាទឹក សាភ្លើង សាចំបើង សាទប់ សាទល់ សាហល់ សាហើម សាផ្កាប់មុខ សា មហាស្រណុក សាដាស់ភ្លើង សាឆ្អឹង ទើបអញដឹងកំណើតសាចាប់ដៃ ដេញដោយសរសៃ ហើមដោះប្រឡោះដើមភ្លៅអញជះ បណ្តេញសាទៅកុំនៅណាសាណា ។ (សូត្រ៧ចប់ ស្តោះផ្លុំ ជាហោង)

ចម្លងតាមក្បួន លោកគ្រូ ពេជ ហៅ ដំបងពេជ (ព្រៃទប់-កំពត)

## មន្តគាថាចងព្រាយ ខ្មោច អាប ធ្មប់

ដែលវាធ្វើឱ្យអ្នកជំងឺរវើរវាយ ឬ ស្រែកយំ

ឱម: សន្ទា មហាសន្ទា ទើបគ្រូប្រើមន្តចងដៃឆេះបីដូចភ្លើងកាល

ឱម: ក្រឡេកឆេះ ឆេះទាំងទឹក ឆេះទាំងដី ឆេះមេព្រាយ កំចាយទាំងក្បាលអាប គំរាមទាំងមេរបស់ចុះក្អួត អង្គុតធ្មេញពេញអណ្តាត ស្រោតសំពត់រត់ចេញទៅ ។

(សូត្រ៧ចប់ ផ្លុំពីកាលឱ្យចេញតាមរន្ធលាមកជាហោង)

ចម្លងតាមក្បួនលោកគ្រូ ច័ន្ទ ដុំ ស្រុកទ្រាំង តាកែវ

------------------------------------,,---





យ័ន្តគាថានេះប្រើត្រូវក្មេងកើតស្គន់ កើតកមរមាស់ ឬបូសខ្ទុរ និងរវើរវាយយប់មិនព្រមដេក មូរក្រដាសយ័ន្តនេះចងក ឬសរសេរនឹងម្លូគូយ័ន្ត ។ នឹកគុណគ្រូប្រសិទ្ធិគាថា ថា ឧ ម អ មិ, ម ហិ សុ តំ (សូត្រ៣ចប់ នឹងជាដូចបំណង)

AZCambodia.com ABCCambodia.com AngkorDaily.com AngkorPost.com AngkorLink.com